**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៤៤៥ សហវ.

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨*

# សារាចរ

## ស្តីពីការណែនាំ

## លើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

## I. សេចក្តីផ្តើម

១- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ និងអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និង អនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៦២៤ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ និង ប្រកាសលេខ ១៦២៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូក តាមគណនី និង អនុគណនីសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ គ្រប់គ្រងឆ្នាំ ២០០៩ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និង សំរេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំលើការអនុវត្តថវិកាទូទៅរបស់រដ្ឋសំរាប់ឆ្នាំ ២០០៩ ដែលមានតាមលំដាប់លំដោយដូចតទៅ ÷

២- ច្បាប់ស្តីពីហិញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស ដើម្បីបំរើឱ្យការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ***ដំណាក់កាលទី ២*** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ នេះ ត្រូវបង្កនូវកត្តាជាបុព្វបទទាំងឡាយ សម្រាប់ឈានទៅសម្រេចបាននូវគោលនយោបាយជាមូលដ្ឋានគ្រឹះខាងសេដ្ឋកិច្ច របស់

រាជរដ្ឋាភិបាលគឺ *«ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាប ក្នុងកម្រិតត្រូវលេខមួយខ្ទង់»* និង *«ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ»* ។

៣- ឆ្នាំ ២០០៩ នេះ គឺជាឆ្នាំទី ១ នៃដើមនីតិកាលទី ៤ ដែលរាជរដ្ឋាភិបាលបានកំណត់នូវឆន្ទៈនយោបាយថានឹងបន្តជំរុញឱ្យកាន់តែស៊ីជំរៅបន្ថែមទៀត លើការដ្ឋានកំណែទម្រង់ និងកម្មវិធីអភិវឌ្ឍសំខាន់ៗ ដែលបាន និងកំពុងបន្តផ្តល់នូវផ្លែផ្កាគួរជាទីលើកទឹកចិត្ត ជាពិសេស ភាពប្រសើរឡើងនៃបរិយាកាសវិនិយោគ ការពង្រឹង និងពង្រីកវិស័យធនាគារ និងទីផ្សារហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍វិស័យឯកជន និង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការសម្រេចបានភាពជឿទុកចិត្តលើថវិកា ហើយឈានទៅចាប់ផ្តើមបង្កើនគណនេយ្យភាពហិរញ្ញវត្ថុនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែលម្អប្រព័ន្ធបៀវត្ស និង ការគ្រប់គ្រងមន្ត្រីរាជការនៃកំណែទម្រង់រដ្ឋបាល ការកែលម្អប្រព័ន្ធចុះបញ្ជីដីធ្លីនៃកំណែទម្រង់ការគ្រប់គ្រងដីធ្លី ការបង្កើនការយល់ដឹង និងការពង្រឹងសេវាច្បាប់នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង ការកែលម្អប្រព័ន្ធបៀវត្ស និងការពង្រឹងការគ្រប់គ្រងកងទ័ពនៃកំណែទម្រង់កងកំលាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនអភិបាលកិច្ចល្អ និងការបង្កើនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលក៏កាន់តែពង្រឹងបាននូវភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ទាំងក្នុងលក្ខណៈទ្វេភាគី ពហុភាគី និងអន្តរជាតិ តាមរយៈជោគជ័យនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ កន្លងទៅនេះ ដែលបានបង្ហាញកាន់តែច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាគឺជាអ្នកកាច់ចង្កូត និងចង្អុលបង្ហាញ ហើយដៃគូអភិវឌ្ឍន៍កាន់តែមានភាពជឿជាក់ និងធ្វើសុខដុមភាវូបនីយកម្មវិភាគទាន របស់ខ្លួនទៅតាមតម្រូវការជាក់ស្តែងរបស់កម្ពុជាដែលបានចែងនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** ***ដំណាក់កាល ទី ២*** ជាមួយនឹងគណនេយ្យភាពទ្វេទិស ។

៤- ដើម្បីសំរេចបានតាមគោលបំណង និងគោលដៅខាងលើ ពិសេស ស្ថិតក្នុងស្ថានភាពដែលពិភពលោកបាន និងកំពុងតែជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដែលបាន និងកំពុងជះឥទ្ធិពលមកលើកម្ពុជា រាជរដ្ឋាភិបាលនឹងបន្តពង្រឹងបន្ថែមទៀតនូវការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាព បន្តជំរុញការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពមោះមុត និង ប្រុងប្រយ័ត្នខ្ពស់ និង បន្តជំរុញការអនុវត្តគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីបន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាពល្អ ។ ការបន្តជំរុញការអនុវត្តគោលនយោបាយ និងកម្មវិធីអាទិភាព ពិសេស លើវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង សង្គមកិច្ច ដូចជា ការបន្តជំរុញកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតាមរយៈការផ្តល់ការលើកទឹកចិត្តសមស្របដល់អ្នក

នឹងកើន ១០៧,៣០% ស្មើនឹង ០,៥៦% នៃផសស និង ចំណូលមិនមែនសារពើពន្ធថវិកាខេត្ត-ក្រុងនឹងថយ ៣,៥០% ស្មើនឹង ០,០៤% នៃផសស ។ រីឯចំណូលមូលធនសរុបនឹងសំរេចបាន ២ ០៨៣ ០០០ លានរៀល គឺកើនឡើង ២១% ស្មើនឹង ៤,៣០% នៃផសស ដែលក្នុងនោះ ចំណូលមូលធនក្នុងប្រទេសមាន ៤៨ ០០០ លានរៀល ស្មើនឹង ០,១០% នៃ ផសស និង ចំណូលមូលធនក្រៅប្រទេសមាន ២ ០៣៥ ០០០ លានរៀល (៣៣៥ ០០០ លានរៀល ជាមូលនិធិទ្រទ្រង់ថវិកា និង ១ ៧០០ ០០០ លានរៀល ជាមូលនិធិវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស) នឹងកើន ២៥,៥០% ស្មើនឹង ៤,២០% នៃផសស ។

៧- ដើម្បីសំរេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្ត និងតាមដានជាប្រចាំនូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលំអិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានភាតព្វកិច្ចប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានជាមធ្យម ១៤១ ៦៦៦ លានរៀល ក្នុងមួយខែ ។ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាមានភាតព្វកិច្ចប្រមូលចំណូលពន្ធ និងអាករឱ្យបានជាមធ្យម ២០០ ០០០ លានរៀល ក្នុងមួយខែ និង ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវប្រមូលឱ្យបានជាមធ្យម ១៤ ៧៨៦ លានរៀល ក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកំរិតខ្ពស់ ឬ ទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដោយ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលំអិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខាទីស្នាក់ការ ឬ/និង មន្ត្រីដែលមានភាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ។

៨- ដើម្បីឱ្យការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០០៩ នេះសំរេចបានតាមគោលដៅ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលំអិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និង សង្វាក់នៃការប្រមូលចំណូលកន្លងមក ព្រមទាំងដាក់ផែនការសកម្មភាព និងវិធានការអនុវត្តលំអិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ ហើយប្រគល់ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និង នៅខេត្ត-ក្រុង ដែលមានភាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ។ អង្គភាពប្រមូលចំណូល ត្រូវធ្វើការតាមដាន និងជំរុញជាប្រចាំ នូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង រិះរកវិធានការទាន់ពេលវេលា ក្នុងករណីចាំបាច់ ជាពិសេសត្រូវគោរព និង អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការអនុវត្តកម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសំរេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗ ត្រូវធ្វើការតាមដាន និងត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាស) លើលទ្ធផលសំរេចបាន ដើម្បីរិះរកវិធានការទាន់

ពេលវេលាក្នុងករណីចាំបាច់ ព្រមទាំងធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាស ស្តីពីការអនុវត្តចំណូលរបស់ខ្លួនសំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងមានវិធានការ តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសំរេចបាន និង ចំណុចខ្វះខាត ដែលបានកត់សំគាល់ ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលម្អ និងបង្កើនប្រសិទ្ធភាពប្រមូលចំណូល ។

៩- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយខាងលើនេះ ជាពិសេស ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដាក់ចេញនូវបណ្តាវិធានការមួយចំនួនដូចខាងក្រោម ÷

***ទីមួយ- ការពង្រឹងសមត្ថភាពរបស់រាប់គ្រប់គ្រង និង ប្រមូលចំណូល***

- បន្តជំរុញការកសាង និង រៀបចំដាក់ឱ្យអនុវត្តនូវបង្កាន់ដៃជាតិមួយដែលឯកភាព សំរាប់ប្រើប្រាស់ក្នុងការចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលគ្រប់ប្រភេទ ។
- បន្តជំរុញការរៀបចំយន្តការ និង ការណែនាំឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
- បន្តជំរុញការសិក្សា និង ស្វែងរកជំរើស ដើម្បីបង្កើនការប្រមូល និង ពង្រីកមូលដ្ឋានប្រមូល ជាពិសេស ជំរុញការសិក្សាស្រាវជ្រាវលើការរុករក និង ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើធនធានប្រេង និង ឧស្ម័ន ។
- បន្តជំរុញការបង្កើតក្របខ័ណ្ឌសំរាប់កៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការ សំដៅបង្កើនធនធានទៅតាមខេត្ត- ក្រុង និង ឃុំ- សង្កាត់ ក្រោមកម្មវិធីវិសហមជ្ឈការសារពើពន្ធ ។
- បន្តជំរុញការកសាងគោលនយោបាយចំណូលរយៈពេលមធ្យម និង វែង ដើម្បីធានានិរន្តភាព និង ស្ថិរភាពនៃហិរញ្ញវត្ថុសាធារណៈក៏ដូចជាម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការធ្វើសមាហរណកម្មនៃការកៀរគរធនធានថវិកា សំដៅបំពីឱ្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង វែង ។
- បន្តជំរុញការអនុវត្ត ***ផែនការយុទ្ធសាស្ត្រថវិកា*** ដែលជាឧបករណ៍ដ៏សំខាន់ សំរាប់ការធ្វើសមាហរណកម្មចំណូលទាំងក្នុង និង ក្រៅប្រទេស ទៅក្នុងដំណើរការនៃការកសាងថវិកាឯកភាពមួយ ដើម្បីបង្កើនភាពគ្រប់ជ្រុងជ្រោយ ងាយប្រមូលសរុប និងងាយត្រួតពិនិត្យការអនុវត្តថវិកា ។
- បន្តជំរុញការកំណត់ឱ្យបានច្បាស់លាស់នូវបំណុលពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារឱ្យមានប្រសិទ្ធភាព ។
- បន្តជំរុញពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទាំងការងារអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការគ្រប់គ្រងថវិកា ជាពិសេសលើការប្រមូលចំណូល ។

***ទីពីរ- ការពង្រឹងការប្រមូលចំណូលពន្ធដារ៖***

- បន្តពង្រឹង និង កែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និង ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និង ឱ្យបានហ្មត់ចត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តា ខេត្ត-ក្រុង និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និង ឧស្ម័ន ។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ។

***ទីបី- ពង្រឹងការប្រមូលចំណូលគយ និងរដ្ឋាករ៖***

- បន្តជំរុញការរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយដែលទើបបានទទួលការអនុម័ត ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ-ចូល និង ក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួលក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- បន្តរៀបចំកែលម្អ និងដាក់ឱ្យអនុវត្តរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែ ខ្លាំងក្លា និង ប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារ អេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ. បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ. បន្តរិះរក និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និង ទន់ភ្លន់* លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។
- បន្តពង្រឹង និង ពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និង យន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន ។
- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។
- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

***ទីបួន- <u>ពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធៈ</u>***

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។
- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

ត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់សុំបើកផ្តល់បន្ថែម សាមីអង្គភាពត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាសផ្តល់កម្មវិធីបន្ថែមនៅក្នុងក្របខ័ណ្ឌ ឥណទានថវិកាដែលមិនទាន់បែងចែកទៅក្នុងកម្មវិធីចំណាយ ។

• អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបញ្ជូនមកនាយកដ្ឋានថវិកា នូវរបាយការណ៍សមតុល្យប្រចាំថ្ងៃ របាយការណ៍ចំណូល- ចំណាយថវិកាប្រចាំខែ តាមរយៈអាណត្តិបើកប្រាក់ និងតាមរយៈបុរេប្រទាន ព្រមទាំងសាលាកប័ត្របង់ប្រាក់ និងតារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល- ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតម្លៃនូវសភាពការណ៍អនុវត្ត ធៀបនឹងខែមុន ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ ត្រីមាសដូចគ្នានៃឆ្នាំមុន ។

• រតនាគារនៅថ្នាក់មូលដ្ឋានត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍ចំណូល- ចំណាយ ថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល- ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និង ដើម្បីឱ្យមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានថវិកា ។

***ខ.២- <u>ការផ្តល់ធានាចំណាយ</u>***

- ទាំងថវិកាកម្មវិធី និង មិនមែនកម្មវិធី ការសុំ និង ការផ្តល់ធានាចំណាយ ត្រូវអនុវត្តទៅតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម៖
  - ***ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)*** ពុំតម្រូវឱ្យមានការសុំធានាចំណាយទេ លើកលែងតែក្រសួងការពារជាតិ ។
  - ***ចំណាយដែលមិនតម្រូវឱ្យអនុវត្តនីតិវិធីវេញថ្លៃជាសាធារណៈ និង ចំណាយដែលមានរបបកំណត់ច្បាស់លាស់*** ពុំតម្រូវឱ្យមានការសុំធានាចំណាយទេ ។ ចំណាយប្រភេទនេះ មានដូចជាការចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន សំរាប់ការទិញ និង សេវាតូចតាចដែលស្ថិតក្នុងនិតិវិធីស្នងថ្លៃ និង ចំណាយលើបេសកកម្ម កិច្ចប្រជុំ សិក្ខាសាលា និងចំណាយឧបត្ថម្ភផ្សេងៗ ដែលមានគោលការណ៍កំណត់រួចហើយ ចំណាយលើអគ្គិសនី ទឹក ទូរសព្ទ ជាដើម ។ល។
  - ***ចំណាយដែលតម្រូវឱ្យអនុវត្តនីតិវិធីវេញថ្លៃជាសាធារណៈ*** តម្រូវឱ្យមានការសុំធានាចំណាយក្នុងមួយលើកៗ សំរាប់រយៈពេល ៦ ខែយ៉ាងតិច ។

• ចំពោះប្រភេទចំណាយដែលមិនតម្រូវឱ្យមានការសុំធានាចំណាយ អាណាប័កត្រូវធ្វើអាណត្តិសុំទូទាត់តែម្តង ដោយមានភ្ជាប់មកជាមួយនូវឯកសារ និង លិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ។

• មិនអនុញ្ញាតឱ្យមានការផ្តល់ធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិនបើគ្មានការស្នើសុំជាលាយល័ក្ខអក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

ក្រុងទាំងអស់ ត្រូវផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីធ្វើការបូកសរុប ហើយផ្ញើមកនាយកដ្ឋានថវិកា សំរាប់ការរៀបចំ កម្មវិធីចំណូល- ចំណាយប្រចាំត្រីមាស និងផ្ញើទៅក្រសួង- ស្ថាប័នតាមខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់សំរាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត ។

១២- ដើម្បីបន្តធានា និងបង្កើនភាពជឿទុកចិត្តបានលើថវិកា ជាពិសេស ដើម្បីបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ការរៀបចំកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និង សុក្រឹត ព្រមទាំងការអនុវត្តឱ្យបានហ្មឹងម៉ាត់តាមកម្មវិធីចំណូល- ចំណាយនេះ គឺជាប្រការចាំបាច់បំផុត ។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តឱ្យបានហ្មឹងម៉ាត់នូវនីតិវិធីដូចខាងក្រោម៖

- នៅរៀងរាល់ថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសកន្លងទៅ និង គំរោងកម្មវិធី ចំណូល- ចំណាយប្រចាំត្រីមាសបន្ទាប់ ។
- អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត- ក្រុង ត្រូវផ្ញើរបាយការណ៍អំពីការអនុវត្តចំណូល- ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ។
- នៅរៀងរាល់ថ្ងៃទី ២៥ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកាត្រូវកោះប្រជុំពិភាក្សា ជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធី ចំណូល- ចំណាយថវិការដ្ឋសំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល- ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើប្រកាសប្រគល់កម្មវិធីចំណូល- ចំណាយសំរាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកាក្នុងកំរិតឥណទានអតិបរមាជូនដល់ក្រសួង- ស្ថាប័ននីមួយៗ និងមន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច អគ្គនាយកដ្ឋានរតនាគារជាតិ និងអភិបាលខេត្ត- ក្រុង ។
- អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានរតនាគារជាតិត្រូវចុះ ទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវបើកជាសាច់ប្រាក់តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំ

០១២ សហវ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការរៀបចំផែនការលទ្ធកម្ម និង បទប្បញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ ។

- តម្លៃសរុបនៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយ ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។
- មិនអនុញ្ញាតឱ្យធ្វើការប្រគល់ទទួលទំនិញ សំណង់ ឬ សេវា ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និង ចាំបាច់បំផុតសំរាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តម្លៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។
- ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការផ្លាស់ប្តូរបញ្ជីម៉ាទំតំលៃ ឬ លក្ខណៈបច្ចេកទេសនៃទំនិញ សំណង់ ឬ សេវា ខុសពីឧបសម្ព័ន្ធនៃកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតម្លៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់ រហូតដល់ផុតរយៈពេលធានាគុណភាព ទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

## *ខ.៤ - ការទូទាត់ និង ការបើកផ្តល់*

- គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ ត្រូវគោរពទៅតាមនីតិវិធី និង បទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ និង ការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេស ត្រូវរៀបចំសំណើសុំធ្វើការទូទាត់ទៅតាមលំដាប់លំដោយនៃកម្មវិធីចំណាយប្រចាំខែ ឱ្យបានទៀងទាត់ ។
- មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសម្រេចដោយឡែក ។
- ត្រូវធ្វើការទូទាត់ និង បញ្ចេញអាណត្តិបើកប្រាក់ ទៅតាមកម្មវិធីចំណូល- ចំណាយដែលបានកំណត់។
- មិនត្រូវអនុវត្តចំណាយ និង មិនត្រូវទូទាត់ជូនចំពោះចំណាយណាដែលគ្មានលិខិតយុត្តិការគ្រប់គ្រាន់។
- មិនត្រូវធ្វើអាណត្តិបើកប្រាក់ និង មិនត្រូវបញ្ជូនអាណត្តិបើកប្រាក់នោះទៅអគ្គនាយកដ្ឋានរតនាគារជាតិបានឡើយ ប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។
- រជ្ជទេយ្យបុរេប្រទានមានពីរប្រភេទគឺ រជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ដែលមានទឹកប្រាក់នៃជំពូកបង្វិល ១ ភាគ ៨ លើ ៣០% នៃឥណទានសរុបលើជំពូកមួយចំនួនដែលមានតម្រូវការចំណាយ តាមរយៈរជ្ជទេយ្យបុរេប្រទាន និង រជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ដែលមានទឹកប្រាក់នៃជំពូកបង្វិល ១ ភាគ ៤ លើ ៣០% នៃឥណទានសរុបលើជំពូកមួយចំនួនដែលមានតម្រូវការចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន ។ ទោះជា រជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ឬ រជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធីក៏ដោយ ចំនួនដងនៃការទូទាត់អាចអនុញ្ញាតឱ្យធ្វើលើសពីចំនួនជំពូកបង្វិល ។ ដូច្នេះ ដីកាបណ្ណាទឹកប្រាក់រជ្ជទេយ្យបុរេប្រទានត្រូវបានចំណាយអស់ពី

• ត្រូវផ្តល់ធានាចំណាយ តែក្នុងកំរិតឥណទានថវិកាដែលបានអនុម័ត ឬ ដែលមាននៅសល់ទំនេរក្រោយពីដកស្តុកលើករាល់ការធានាចំណាយ និង ការចំណាយជាក់ស្តែង រួមទាំងថវិកាបុរេប្រទានផង ។

• មិនត្រូវផ្តល់ធានាចំណាយឱ្យលើសពីឥណទានថវិកាដែលមានលក្ខណៈកំរិតកំណត់ ។

• មិនត្រូវផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាព ដែលនាំឱ្យមានការជ្រើសរើសបុគ្គលិក ថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យា នៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

• មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំចេញពីខ្ទង់ចំណាយដទៃមកធានា ។

• ក្នុងការផ្តល់ធានាចំណាយមិនត្រូវកាត់បន្ថយសកម្មភាពការងារ អនុកម្មវិធី ឬកម្មវិធីដែលបានអនុម័តរួចហើយនោះទេ លើកលែងតែមានការស្នើសុំពីសាមីក្រសួង-ស្ថាប័ន ដោយមានបញ្ជាក់ពីហេតុផល និងផលប៉ះពាល់ច្បាស់លាស់ ហើយធានាថាមិនធ្វើឱ្យប៉ះពាល់ដល់ការសំរេចគោលដៅសូចនាករ នៃគោលនយោបាយរបស់ក្រសួង-ស្ថាប័នដែលបានកំណត់ ឬ គោលនយោបាយរបស់វិស័យ និង គោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ។

## ខ.៣- ការធ្វើលទ្ធកម្មសាធារណៈ

• ការធ្វើលទ្ធកម្មសាធារណៈ គឺអនុវត្តលើចំណាយដែលតម្រូវឱ្យអនុវត្តនីតិវិធីដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ និងពិគ្រោះថ្លៃ ហើយត្រូវរៀបចំចងជា «ឡូតិ៍លទ្ធកម្ម» ឬ «កញ្ចប់លទ្ធកម្ម» ចំពោះប្រភេទទំនិញ និង សំណង់ ដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា តែមិនត្រូវចងជា «ឡូតិ៍លទ្ធកម្ម» ឬ «កញ្ចប់លទ្ធកម្ម» រវាងក្រសួង-ស្ថាប័ន អង្គភាព និង មន្ទីរជំនាញខេត្ត-ក្រុង ដែលមានកញ្ចប់ថវិកាដោយឡែកពីគ្នានៅក្នុងសៀវភៅថវិកាទេ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយផ្អែកលើតម្រូវការជាក់ស្តែង និង គោរពទៅតាមវិធីសាស្រ្ត និង នីតិវិធីលទ្ធកម្មសាធារណៈ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្ម) ដើម្បីពិនិត្យ និង ផ្តល់ការឯកភាព ។

• ការធ្វើលទ្ធកម្មសាធារណៈត្រូវអនុវត្តឱ្យបានទៀងទាត់ និង ទៅតាមប្រតិទិន ដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម ដែលបានឯកភាពដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការធ្វើលទ្ធកម្មដែលមិនស្ថិតនៅក្នុងផែនការលទ្ធកម្មនឹងមិនត្រូវបានទទួលស្គាល់ និង មិនធ្វើការទូទាត់ជូនទេ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវផ្ញើរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តលទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យា និង ការងារវិសោធនកម្មបជ្ឈការ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឱ្យបានទៀងទាត់ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគោរពឱ្យបានហ្មត់ចត់ ទៅតាមអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ

• ចំណាយចរិការដ្ឋក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និងសាងសង់ ត្រូវតែអនុវត្តឱ្យបានហ្មឹងម៉ាត់តាមគោលការណ៍ និង នីតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃសាធារណៈ ត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយ ឱ្យបានទាន់ពេលវេលា មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។ កន្លងមក សាមីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ មិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែឥណទានចរិកាដែលបានកំណត់នៅក្នុងសៀវភៅចរិកាតែប៉ុណ្ណោះ ប៉ុន្តែកម្មវិធីចំណាយត្រូវតែជាក់ស្តែង និង សុក្រឹត ព្រោះវាជាមូលដ្ឋានសំរាប់ការរៀបចំផែនការសាច់ប្រាក់សំរាប់ការបើកផ្តល់ ។

### ខ.៥ - ការអនុវត្តបៀវត្ស ប្រាក់បំណាច់ និង កន្សោមអាទិភាព

១៥- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវតែពិនិត្យអនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៩០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និង ដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព អនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់ មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹតលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និង តារាងទូទាត់ ប្រាក់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាដែលចេញដោយ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និង គ្រោងបៀវត្សនៅក្រសួង-ស្ថាប័ន ដែលបានផ្ទេរចូលឱ្យទាន់ពេលនៅឆ្នាំបន្ទាប់ ។ ចំពោះការអនុវត្តកន្សោមអាទិភាព ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ក្រោយពីបាន ទទួលសេចក្តីសំរេចពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើសំណើសុំចរិកាមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបន្ទាន់ ដើម្បីឱ្យការអនុវត្តកន្សោមអាទិភាពនេះ ប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។ ចំពោះកម្មវិធីកន្សោមអាទិភាពដែលត្រូវអនុវត្តបន្ត ត្រូវធ្វើសំណើសុំចរិកាមកក្រសួងសេដ្ឋកិច្ច

៧០% ឡើងទៅ ត្រូវរៀបចំឯកសារទូទាត់លើខ្ទង់ដែលបានចំណាយ និង សុំបំពេញបេឡាវដ្ដទេយ្យបុរេប្រទានឡើងវិញ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទូទាត់ផង និង ដើម្បីកុំឱ្យស្ទះការងារផង ។

- អាចផ្ដល់ថវិកាបុរេប្រទានបាន តែក្នុងករណីចាំបាច់ បន្ទាន់ និង មានឥណទានសល់ទំនេរសំរាប់ចេញអាណត្តិទូទាត់បានក្រោយពីប្រតិបត្តិការចំណាយរួច ។
- អាចផ្ដល់មូលនិធិផ្គួសផ្គុល-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។
- ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល ដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងករណីតម្លៃកិច្ចសន្យាមានចំនួនទឹកប្រាក់ច្រើនដល់រាប់ពាន់លានរៀលនោះ ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងជាច្រើនជំហានទៅតាមលទ្ធភាពនៃសាច់ប្រាក់ ។

១៣- ទន្ទឹមនឹងការអនុវត្តចំណាយទៅតាមកម្មវិធីចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ ត្រូវផ្ដល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់ សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស និង បន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ស្ថិតក្នុងស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោកដែលបាន និងកំពុងមានវិបត្តិ ហើយក៏បាន និងកំពុងជះឥទ្ធិពលមកលើកម្ពុជា ដែលអាចនឹងប៉ះពាល់ដល់ការអនុវត្តថវិកាជាយថាហេតុ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបង្កើនការសន្សំសំចៃកំរិតខ្ពស់ ពិសេសលើចំណាយរដ្ឋបាល ដូចជា ប្រេងឥន្ធនៈ សំភារៈការិយាល័យ អគ្គិសនី ទឹក ទូរស័ព្ទ ព្រមទាំងចំណាយរដ្ឋបាលផ្សេងៗ ដោយបង្កើនការគ្រប់គ្រងចំណាយឱ្យកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ព្រមទាំង ធ្វើអាទិភាពកម្មឡើងវិញក្នុងករណីចាំបាច់ដើម្បីត្រៀមកាត់បន្ថយចំណាយ ដើម្បីរួមចំណែករក្សាតុល្យភាពថវិកា ស្ថិរភាពថ្លៃស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

១៤- ដើម្បីឱ្យការអនុវត្តចំណាយថវិការដ្ឋប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្ដុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញនៅតាមខេត្ត-ក្រុង ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និងអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ៖

- រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្ដីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកាជូនអភិបាលខេត្ត-ក្រុង ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង អាចអនុវត្តនីតិវិធីចំណាយបានទាន់ពេលវេលា ។

និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍នៃការអនុវត្តកម្មវិធីកន្សោមអាទិភាពកន្លងមក និង សេចក្តីសំរេចរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

### ខ.៦ - ការផ្ទេរឥណទានថវិកា

១៦- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ នៅដើមត្រីមាសទី ៣ ក្រោយពីការអនុវត្តត្រីមាសទី ២ ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សំរេចជាមុនសិន ទើបអាចលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ បើក្រសួងស្ថាប័នមានសំណូមពរផ្តល់ឥណទានបន្ថែមសម្រាប់ផ្តល់ទៅឱ្យមន្ទីរជំនាញខេត្ត-ក្រុងរបស់ខ្លួន គឺការផ្តល់ឥណទានបន្ថែមនោះ ត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។

## III. ការតាមដានការអនុវត្តថវិកា និង ការធ្វើរបាយការណ៍

១៧- ដើម្បីបង្កើនគណនេយ្យភាព និង ការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវធ្វើការតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និង ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ឱ្យបានទៀងទាត់ ទៅតាមគំរូ ដែលបានផ្ញើជូន និង នៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែ នៅដើមត្រីមាសបន្ទាប់
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មិថុនា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០

## IV. វិធានការរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា

១៨- នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសំរេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោម៖

• ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិ ដើម្បីបន្តបង្កើនការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៅកម្ពុជា ។

• ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ ក្នុងការតាមដានការអនុវត្តថវិកា និង សកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលបាន និងកំពុងប្រែប្រួលស្ទើរតែមិនអាចព្យាករណ៍បាន ប្រកបដោយលក្ខណៈសកម្មគ្រប់គ្រង ។

• ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់ ។

• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនអនុញ្ញាតឱ្យមានការបោះផ្សាយអាណត្តិតំកល់ទុកសំរាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ខេត្ត- ក្រុងទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៩ របស់យើងឱ្យសំរេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបំរើឱ្យការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ***ដំណាក់កាលទី ២*** របស់រាជរដ្ឋាភិបាល ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** និង ឆ្លើយតបទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដើម្បី **កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន** ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចំលងជូន</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់ខេត្ត- ក្រុង

"ដើម្បីអនុវត្ត"

- រាជកិច្ច

"ដើម្បីផ្សព្វផ្សាយ"

- ឯកសារ-កាលប្បវត្តិ